ឧបសោសង្ហាំ

# បញ្ញវន្ត និង មនោគមវិជ្ជានយោបាយ




## សាកល្បងពិចារណា

**មាតិការឿង**

សេចក្តីផ្តើម ........................................ 2
អង្គហេតុធំៗ នៅលើពិភពលោក .................. 5
ការពិភាក្សា នៃមនោគមវិជ្ជាអង់គ្លេស ..... 11
ការពិភាក្សា នៃមនោគមវិជ្ជាអាមេរិកាំង 12
ការពិភាក្សា នៃមនោគមវិជ្ជាបារាំងសែស 15
នៅប្រទេសមិនមែនជាមស្លិមប្រទេស ...... 17
ករណីនៅស្រុកខ្មែរ ..................................... 18

# សេចក្តីផ្តើម

នៅស្រុកខ្មែរសព្វថ្ងៃ ហាក់បីដូចមានកង្វះ នូវការជជែកវែកញែក នៃបញ្ហានយោបាយ ដែលនាំចោទជាសំនួរថា តើថ្នាក់ នៃបញ្ញវន្តខ្មែរ មាននូវមនោគមវិជ្ជានយោបាយផ្ទាល់ខ្លួនដែរឬទេ ? គេដឹងថា ស្រុកខ្មែរ ក្រោយសម័យអង្គរ បានបាត់ស្ទើរអស់ នូវមរតក នៃបញ្ញា នយោបាយបុព្វបុរស របស់ខ្លួន ធ្លាក់ខ្លួន ជាប្រទេសខ្ញុំបរទេស រហូតមកដល់សព្វថ្ងៃ។ ស្ថិតនៅក្រោមការត្រួតត្រាបរទេសនេះ គេនឹកក្នុងចិត្តថា តើវានាំអោយបញ្ញាខ្មែរ ស្ថិតនៅក្រោមឥទ្ធិពល បញ្ញាបរទេស មាន :សៀម យួន, បារាំង, ចិន, អាមេរិកាំង ជាអាទិ៍ ?

នៅទីនេះ ជាបឋម យើងលើកយក សិល្បៈ នៃបញ្ញវន្តរបស់ប្រទេសមហាអំណាច ដែលបានជះឥទ្ធិពលខ្លួន នៅលើពិភពលោក គឺប្រទេស អង់គ្លេស, បារាំង និង សហរដ្ឋអាមេរិក, មកធ្វើជាគោល នៃការពិចារណា ស្វែងរក ជំហរនៃបញ្ញាខ្មែរ ដែលជាប់ទាក់ទងនឹងបញ្ញា ដែលមាននៅលើលោកនេះ។ យើងមិនទុក មនោគមវិជ្ជា កុម្មុយនិស្តជាបញ្ញានោះឡើយ ព្រោះ វាខាយាំង នូវការពិភាក្សា នៃបញ្ញា ទោះបី មនោគមវិជ្ជានេះ វាស្ថិតនៅចំកណ្តាល នៃការប្រយុទ្ធមតិ រវាង លោកសេរី និង កុម្មុយនិស្ត អស់រយៈពេលជិតមួយសតវត្សក៏ដោយ។

ជាបឋម គេអាចនិយាយបានថា សិល្បៈ នៃបញ្ញាវន្ត អង់គ្លេស គឺជាសិល្បៈ នៃការបង្រួញ នៃទំនាស់មនោគមវិជ្ជា ដោយប្រើពាក្យបច្ចេកទេស ដើម្បីបង្ហាញ នូវរូបភាព នៃទំនាស់ អោយស្រួលយល់ និង បន្ថយ នូវសេចក្តីក្រៀវក្រោធ នៃការពិភាក្សា។ ចំណែកឯ សិល្បៈ នៃបញ្ញវន្តអាមេរិកាំង វិញ គឺ ផ្លាស់ទ្រង់ទ្រាយ នូវអ្វីដែលជា ភាពចម្រូងចម្រាស ក្នុងទំនាស់ នៃគំនិត អោយទៅជា វិវាទ នៃសីលធម៌។ សិល្បៈនេះ មានគោលបំណងចង់បង្ហាញ នូវវិធីសាស្ត្រ សំរាប់ដោះស្រាយ ជាងចង្អុលប្រាប់ភ្លាម នូវការដោះស្រាយ។ ចំណែកខាង បារាំងសែស វិញ គឺ មិនធ្វើដឹងឮអំពីបញ្ហា ដោយលើកយកតែគោលគំនិត របស់ខ្លួន ជាសេចក្តីសំអាងដាច់ខាត ដែលនាំ ជួនកាល ធ្វើវាអោយបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារឆន្ទៈឡឹត របស់ខ្លួន ដ្បិតយល់ឃើញថា គោលគំនិត របស់ខ្លួននោះ វាអាចគិតបាន អំពីបញ្ហា នៃមនុស្សជាតិបានទាំងមូល។

គេដឹងថា មនោគមវិជ្ជានយោបាយ វាតែងតែ មានទំនាក់ទំនងតិចច្រើននឹង សុភមង្គល, សំណើរ នៃការដោះស្រាយ នៃបញ្ហា និង ការវិនិច្ឆ័យ នៃតម្លៃអ្វីមួយ។ វាសំដែងគំនិត នូវទស្សនវិស័យ នៃពិភពលោក និង ឆន្ទៈសំដៅទៅរកអនាគត។ វាមិនធ្លាក់ស្ថិតនៅក្រោមជម្រើស នៃ អ្វីមួយ ដែលបញ្ជាក់ថា ពិត និង មិនពិត នោះទេ ហើយ វាក៏មិនមែនជាកម្មសិទ្ធ របស់លំដាប់ នៃរស់ជាតិ

និង ការលាបពណ៌អ្វីនោះដែរ។ គោលដៅ នៃទស្សនវិជ្ជា និង ឋានានុក្រម នៃមនោគមវិជ្ជានយោបាយ គឺ ការអំពាវនាវ រក នូវការសន្ទនា ជាជាង រក នូវព័ស្តុតាង យកមកផ្គាញ់ផ្គាលគ្នា ដើម្បីយកឈ្នះដាច់ខាត ឬ ធ្វើជា ព័ស្តុតាងបដិសេធ ; វិភាគ លើព្រឹត្តិការណ៍បច្ចុប្បន្ន ឬគិតដល់អនាគត ដែលវាតែងតែវិវត្ត តាមការចេះដឹង នៃមនុស្សជាតិ ដែលលាតត្រដាង ដោយប្រវត្តិសាស្ត្រ។ ដូច្នេះ ទុកការពិសោធគ្រប់បែបយ៉ាង ជាចំណេះចេះដឹង នៃមនុស្សជាតិ ជាមូលដ្ឋាន សំរាប់កែតម្រូវបន្តិចម្តងៗ នូវការស្ថាបនា នៃមនោគមវិជ្ជា។

នៅមស្ហិមប្រទេស, បរិយាកាស បន្ទាប់ពីសង្គ្រាមលោកលើកទី២ គឺ អភិរក្ស។ នៅពេលនោះ, ប្រសិន សហភាពសូវៀត វា មិនជាប្រទេស មានទំនងជា អ្នកគំរាម ដល់លោកសេរី, ប្រសិន ចិនកុម្មុយនិស្ត ក្រោយពីដេញ មស្ហិមប្រទេសចេញពីស្រុកចិនបាន តែបន្ទាប់មក ហាក់បីដូចជាដាស់ នូវរបាលចក្រពត្រលឿង (fantôme d'un impérialisme jaune) នៅអាស៊ី និង ប្រសិន គ្រាប់បែកបរមាណូ មិនជាការថប់បារម្ភ, ប្រហែលជា មស្ហិមប្រទេស និង សហរដ្ឋអាមេរិក អាស្រ័យផល នូវសន្តិភាពឡើងវិញ នៅក្នុង អភិមនៈ នៃភាពរុងរឿងតែឯង នៅមស្ហិមប្រទេស និង ព្រហ្មចារិភាព ផាសុក នៅសហរដ្ឋអាមេរិក ក្រោយពីខ្លួន បានប្រព្រឹត្ត នូវអំពើមិនគាប់បីជាច្រើន។

អង្គហេតុទាំងឡាយនេះ នាំអោយមានកើត នូវសង្គ្រាមត្រជាក់ រវាង លោកសេរី នឹង លោកកុម្មុយនិស្ត បន្ត ពីសង្គ្រាមលោកទី២ ដែលនាំអោយបន្តមាន នូវបដិវត្តន៍ហិង្សាគ្រប់ទីកន្លែង នៅលើលោក។ នៅស្រុកចិន បក្សកុម្មុយនិស្ត យក លទ្ធិម៉ាក្ស មកជំនួស លទ្ធិខុងជឺ, នៅឥណ្ឌា ពួកសហជីវិន របស់លោក គន្ធី នាំគ្នាស្រម័យបង្កើត នូវឧស្សាហកម្មធំៗដូចនៅចក្រភពអង់គ្លេស និងនៅក្នុង អតីតប្រទេសអាណាគម ជាច្រើន មានកើត សង្គ្រាម ទាមទារ នូវសេរីភាព និង ឯករាជ្យជាតិ និងបដិវត្តន៍ ដើម្បី រំលំរបបផ្តាច់ការ គ្រប់ទ្រង់ទ្រាយ។

## អង្គហេតុធំៗ នៅលើពិភពលោក

### សំណួរលើ[1] គំរូសេដ្ឋកិច្ច

នៅមស្ចិមប្រទេស មានទំនាស់រវាង មូលធនិយម នឹងសង្គមនិយម ដែលនាំអោយបាត់បង់ នូវសក្តានុពលផ្លូវចិត្ត[2] នៃខ្លួន។ ដោយហេតុថា គេច្រឡំ សហភាពសូវៀតជាមួយនឹង សង្គមនិយម ព្រោះ មនោគមវិជ្ជា នៃសហរដ្ឋសូវៀត បានបោះបង់ចោលទាំងស្រុង នូវមរតក នៃមូលធននិយម, ហើយអះអាងថាសង្គមនិយម របស់ខ្លួន គឺ

[1] La mise en question.
[2] Potentiel affectif.

បង្កើន ដោយខ្លួនឯង នូវកម្លាំង សំរាប់បង្កើតផល ហើយ គ្មានអ្វី ដែល សង្គមនិយម ស្នើ ផ្ទើបន្ត សព្វអន្លើ នូវរបប កម្មសិទ្ធឯកជននោះឡើយ។ តែតាមពិត ទំនាស់នោះ វា គ្មានឥទ្ធិពលទៅលើ គំនិត នៃស្របនិយម រវាង លំដាប់ នៃការលូតលាស់ និង ដំណើរបន្តពី របប មូលធននិយម ទៅ សង្គមនិយម នោះទេ ព្រោះ ការលូតលាស់ វាមាន វិធានតែមួយ នៅក្រោមច្បាប់សេដ្ឋកិច្ច។ ដូច្នេះនៅក្នុង សង្គមថ្មី ដាក់ឈ្មោះហៅថា សង្គមនិយម វា រកឃើញ មូល ធននិយមឡើងវិញ ដោយគ្រាន់តែប្រែទ្រង់ទ្រាយលំនាំ នូវ ការចាំបាច់ មានជាប់ជាមួយនឹងប្រព័ន្ធទំនើប តែ ប៉ុណ្ណោះ។ គេឃើញ នៅក្នុង របបសង្គមនិយម នៅគ្រប់ទី កន្លែងលើលោក គឺ អ្នកដឹកនាំ នៅតែជា អ្នកសម្រេច គ្រប់អ្វីទាំងអស់ ដូចគ្នានឹង របបមូលធននោះដែរ។ នៅ សហភាពសូវៀត ពួកនាយក នៃរោងចក្រ ក៏ត្រឡប់គិត ឡើងវិញអំពី ការខាត និង ចំណេញ ដូចនៅមស្ចិ មប្រទេស ក្រោយពីទទួលរង នូវបរាជ័យ នៃប្រព័ន្ធ នៃ ផែនការសេដ្ឋកិច្ច។

## សំណួរលើ ស្ថាប័ន

រហូតមកដល់ឆ្នាំ ១៩១៤, គំនិតសំខាន់ៗ នៃពួកឆ្វេង និយម នៅមស្ចិមប្រទេស គឺ ការពារ និង ធ្វើអោយប្រសើរ នូវគំនិត សេរីភាព ដែលជាគំរូដល់ប្រទេស មិនមែនជាម

ស្ថិមប្រទេស ដូចយ៉ាង សេរីភាព នៃសារព័ត៌មាន, ការបោះឆ្នោតសាកល, និង សភា ជាអ្នកសម្រេចកិច្ចការជាតិ។ ស្ថាប័ន សភា វាហាក់បីជា ស្នាដៃឯក នៅអឺរ៉ុប ដែលពួកបញ្ញាវន្ត នៅលើលោក ស្រម័យ ចង់យកមកធ្វើតាមអោយដូចបេះបិទ។

តែនៅចន្លោះ សង្គ្រាមលោក លើកទី១ និង លើកទី២ របបសភា បានក្ស័យទន នៅអឺរ៉ុប។ ការណ៍នេះ នាំបើកឱកាសអោយ សហភាពសូវៀត អាចពន្យល់វែកញែកយ៉ាងជាក់លាក់ថា របបពហុបក្ស និង រដ្ឋាភិបាល មានការពិភាក្សាសេរី វាគ្មានឫទ្ធានុភាពដាច់ខាត ដែលសង្គមអាស៊ី ចង់បង្វេះយកធ្វើជាគំរូ ពីប្រទេសអាណានិគម ដែលជាចៅហ្វាយខ្លួននោះទេ។ ម្យ៉ាងមួយទៀត វិបត្តិ នៅ សហរដ្ឋអាមេរិក, អឺរ៉ុបខាងកើត, មជ្ឈឹមបូព៌ាប្រទេស ដែលធ្វើអោយពិការ ដល់ដំណើរ នៃប្រជាធិបតេយ្យសេរី វានាំឲមានមន្ទិលដល់លទ្ធភាព នូវទំនៀមជាតិ របស់ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក យកមកអនុវត្តនៅក្នុងប្រទេសផ្សេងទៀត ដូចយ៉ាង ប្រព័ន្ធតំណាង ដែល សភាអង់គ្លេស និង សហរដ្ឋអាមេរិក ផ្តល់ជាគំរូរួចស្រេច ទុកអោយ ក្រុមវិជ្ជាជីវៈ, សហជីព, គ្រួសារចិត្តគំនិត, បុគ្គលមានសិទ្ធិការពារអត្ថប្រយោជន៏ និង ជជែកគ្នា មុន និង កំពុងធ្វើសកម្មភាព។ ព្រោះថាគំរូនោះ វាតម្រូវអោយមានបុគ្គលិកមានសមត្ថភាពអាចរក្សានូវភាពចម្រូងចម្រាស

ចេះប្រមាណ, ថ្នាក់អ្នកដឹកនាំ មានមនសិការជាតិ នៃការរួបរួមគ្នា និង សម្រេចចិត្តនឹងធ្វើពលិកម្ម ប្រសិនបើត្រូវធ្វើចាំបាច់។ ពុំនោះសោត វានឹងគាំរាមទៅវិញ ដោយជម្លោះហួសហេតុ, ដោយ គំនិតអភិរក្សនិយម ខ្វាក់ភ្នែកគិតតែពីការពារ នូវបុព្វសិទ្ធិ, ដោយ ភាពទន់ខ្សោយ នៃថ្នាក់សង្គមមធ្យម ដែលជា ស្រទាប់ នៃស្ថេរភាពសង្គម។

ការពិភាក្សារក នូវជម្រើសជំនួស (alternative) នៃសេរីភាព និង ការរីកចំរើនសេដ្ឋកិច្ច, របបសភា ឬ របបប្រធានាធិបតី រវាង ពួកឆ្វេងសេរីនិយម និង ពួកឆ្វេងសង្គមនិយម វាមិនពិត ទុកជា ជម្លោះមនោគមវិជ្ជានោះទេនៅមស្ជិមប្រទេស ព្រោះវាស្ថិតនៅក្រោម វិធានសេដ្ឋកិច្ចតែមួយ។ តែ ជម្រើសជំនួសនោះ វាមានសារៈប្រយោជន៍ ហើយ មិនអាចជៀសវាងបានដែរ នៅក្នុងកាលៈទេសៈខ្លះ។ ការជឿនលឿន ដល់ឋានៈទី១ នៃប្រទេសណាមួយដែលមិនមែនជាប្រទេសមហាអំណាច មូលធននិយម នាំអោយប្រទេសដទៃទៀត ជំពាក់ចិត្ត ទៅលើ រូបមន្តវទ្ធិមួយថា « មស្ជិមរូបណីយកម្ម គ្មានសេរីភាព » ឬ « មស្ជិមរូបណីកម្ម ប្រឆាំងនឹង មស្ជិមប្រទេស » វាក៏ជាផ្លូវ អភិវឌ្ឍន៍អាចធ្វើបានមួយដែរ។

## អប្បដិបត្តិកម្ម[3] នៃមូលធននិយម

មកដល់ចុងសតវត្សទី១៩ មានភាពរងាំ រវាង បញ្ញវន្ត នៅមស្ជិមប្រទេស គឺនាំគ្នា ថ្កោលទោសដល់មូលធននិយម។ មកដល់សតវត្សទី២០ ពួកអ្នកមានសញ្ញាប័ត្រ នៅ អាស៊ី និង អាហ្វ្រិក មានទំនោរ យកទ្រឹស្តីម៉ាក្ស ជាមាគ៌ា សំរាប់កសាងប្រទេសខ្លួន។ លោក ម៉ាក្ស បានសង្កេតថា : « *ក្រុមហ៊ុន និង ឧស្សាហកម្មធំៗ សាងនៅ ទីក្រុង ហុងកុង, នៅប្រទេសម៉ាឡេស៊ី, ឥណ្ឌា មើលទៅដូចជា មូលធននិយម តែវាខុសគ្នានឹង សហរដ្ឋអាមេរិក ឬ ប្រទេសបារាំង។ ព្រោះថា នៅមស្ជិមប្រទេស, សារៈសំខាន់ គឺស្វែងរក ការចំណេញ, បេសកកម្មសាសនា គឺការលាក់បាំង ចំណុច នៃកិត្តិយស នៃប្រយោជន៍ឥតអៀនខ្មាស់, តែនៅទីបញ្ចប់ខ្លួនឯង ទទួលរងគ្រោះពី រូបធាតុនិយម នៃខ្លួនតែម្តង។ មស្ជិមប្រទេស ត្រូវតែហួរហែកគ្នា តាមសង្គ្រាមចក្រពត្រ* »។ តែអ្នកជំទាស់នឹងទ្រឹស្តីម៉ាក្ស យល់ឃើញថា ការបកស្រាយបែបនេះ វាជាគំនិតលំអៀង, មិនពេញលេញ, អយុត្តិធម៌ : ជាការបកស្រាយ មិនពិត ដែលអាចកៀគរប្រជាពលរដ្ឋទាំងឡាយ ឲដើបប្រឆាំងនឹងចៅហ្វាយខ្លួននោះឡើយ។ ដូចយ៉ាងនៅអាស៊ី ប្រទេសខ្លះ អ្នកចេះដឹងយល់ព្រមនឹងទ្រឹស្តីម៉ាក្ស តែប្តូរខ្លឹមសារ ដែលត្រូវយកមក

---
[3] ការមិនប្រតិបត្តិតាម។

អនុវត្ត ព្រោះទ្រឹស្តីនោះ វាមិនអាចជាចម្លើយចំនឹងបញ្ហា នៃសង្គមបានទាំងអស់នោះទេ។

## ដំណើរបែកមតិ រវាង ជុំរុំសូវៀត និង មស្ចឹមប្រទេស

ប្រទេសអាស៊ី ដែលជា អតីតអាណានិគម អង់គ្លេស និង បារាំង មួយចំនួន យកគំរូឧស្សាហកម្មសូវៀត រួចបង្ហាញ ទឹកចិត្តជាទំនាស់ថា ខ្លួនគ្មានជំពាក់គុណអ្វីបន្តិចសោះ ឡើយ ដល់អតីតចៅហ្វាយខ្លួន ព្រោះរយៈពេលអាណា និគម ដ៏យូរលង់ វាជាទុក្ខសោកសុទ្ធសាត ចំពោះខ្លួន ហើយ យល់ឃើញថែមទៀតថា ប្រវត្តិសាស្ត្រ នៃប្រជាជាតិ ខ្លួន វាប្រសើរជាងមស្ចិមប្រទេសទៅទៀត។ ដូច្នេះ គំរូសូវៀ ត ជាមាគ៌ាថ្មីមួយ ខុសពីចៅហ្វាយខ្លួន សំរាប់ធ្វើអភិវឌ្ឍន៍ ដើម្បីកសាងប្រទេសថ្មី។ គំនិតនេះ នាំអោយ អាមេរិកាំង និង មស្ចិមប្រទេស ជាតំណាង នៃលោកសេរី យល់ឃើញ ផ្ទុយថា គំរូសូវៀត ជាគំរូ លុបបំបាត់ នូវសេរីភាព នៃការ ពិភាក្សា រវាង បក្ស និង បក្ស, រវាង សភា និង សភា, រវាង បញ្ញាវន្ត និង បញ្ញាវន្ត, ជួនកាល រវាង អ្នកប្រាជ្ញ និង អ្នក ប្រាជ្ញ។ ដូច្នេះ វាជា គំរូ ប្រកបដោយគ្រោះថ្នាក់ធំណាស់ សំ រាប់សេរីភាព នៃប្រជាពលរដ្ឋ នៅលើពិភពលោក។

ការពិភាក្សា រវាង មនោគមវិជ្ជា មូលធននិយម និង សង្គមនិយម មានបន្ត ហើយប្តូរ ទម្រង់ជាសង្គ្រាមត្រជាក់ រវាង លោកសេរី និង លោកកុម្មុយនិស្ត។ នៅក្នុងសង្គ្រាម

ក្រោយមកនោះ មានកើតសង្គ្រាមអារុជមួយចំនួន នៅលើពិភពលោក។ សង្គ្រាមដែលមានឈ្មោះល្បីល្បាញជាងគេ គឺសង្គ្រាមនៅ ប្រទេសវៀតណាម ដែលមានមហាអំណាចនៃលោកទាំងសងខាង ជាអ្នកផ្តល់ នូវជំនួយគ្រប់បែបយ៉ាងដល់ដៃគូខ្លួន។

## ការពិភាក្សា នៃមនោគមវិជ្ជាអង់គ្លេស

ដូចយើង បានធ្វើសង្ខេបជូនខាងលើរួចហើយថា ពួកបញ្ញាវន្តអង់គ្លេស ទុកការពិភាក្សា នៃមនោគមវិជ្ជានយោបាយជា បញ្ហាបច្ចេកទេស ព្រោះគេយល់ឃើញថាជាបញ្ហា នៃគណនេយ្យ និង គ្មានការទំនាស់ នៃតម្លៃមនោគមវិជ្ជានោះឡើយ។ សារៈសំខាន់ គឺស្ថិតនៅលើបញ្ហា នៃជម្រើស ដែលបច្ចេកទេស ផ្តល់ នូវមធ្យោបាយ ដែលអាចយកមកអនុវត្ត សំរាប់ដោះស្រាយបញ្ហា។ ហេតុនេះឯង បានជាពួកបញ្ញាវន្តអង់គ្លេស មិនសូវរវល់យកចិត្តទុកដាក់នឹង ជម្លោះមនោគមវិជ្ជា ហើយ មិនដឹងថា វាកើតមកពីអ្វីនោះផង។ ការប្រឆាំងនឹង ថ្នាក់ដឹកនាំ និងតម្រេកសង្គម, ការមើលងាយ នៃលំដាប់ស័ក្ក ត្រូវបានគេជៀសវាង និង បំបិទចោល ទោះបីប្រទេសជួបប្រទះនឹងសង្គ្រាមលោកពីរដងក៏ដោយ។ តែការណ៍នេះ វាគ្មានការ

ធានាថា សង្គមអង់គ្លេស អាចជៀសវាងរហូត នូវការប្រេះឆាសង្គម ដូចអឺរ៉ុបនោះឡើយ។

## ការពិភាក្សា នៃមនោគមវិជ្ជាអាមេរិកាំង

ការពិភាក្សា អាមេរិកាំង មានគ្រឹះប្រហាក់ប្រហែលនឹងអង់គ្លេស តែ អាមេរិកាំង មាន រចនាបថ ខុសពីអង់គ្លេស។ អាមេរិកាំង មិនស្គាល់ នូវទំនាស់មនោគមវិជ្ជាដូចរបៀបយល់ឃើញ របស់បារាំងសែសនោះទេ ព្រោះ ពួកបញ្ញវន្តអាមេរិកាំង មិនជាប់ទាក់ទងនឹងគោលលទ្ធិ ឬផ្ទាក់ប្រឆាំងគ្នា និង ប្រតិនិក្ខេបបទ ដូចពួកបារាំងសែសទេ។ នៅសហរដ្ឋអាមេរិក គេមិនឃើញមាន ប្រពៃណី និងវណ្ណៈសង្គម ដែលមាននៅអឺរ៉ុប។ វណ្ណៈអភិជន និង រចនាបថ នៃវណ្ណៈ ត្រូវបានកំទិចចោលគ្មានមេត្តា នៅពេលសង្គ្រាមបែងចែកទឹកដី។ ទស្សនវិជ្ជាសុទិដ្ឋិនិយម នៃសម័យពន្លឺបញ្ញា (Lumières), សមភាព នៃជោគវាសនា សំរាប់ទាំងអស់គ្នា, ការរក្សាស្មារតី លើជម្មជាតិ គឺ មិនញែកដាច់ពី គំនិត ដែលជនអាមេរិកាំងទាំងឡាយ បានកសាងប្រវត្តិសាស្ត្រប្រជាជាតិ និង វាសនា នៃខ្លួន គឺ មានគ្រឹះជាសេរីភាព : សេរីភាពនយោបាយ, សេរីភាពបញ្ចេញមតិ, សេរី ការពារ នៃសេចក្តីស្រេកឃ្លាន និង សេរីភាព រកជម្រកការពារ នូវការភិតភ័យ។ ភាពបាក់ចិត្តទៅរកស

សាសនា វាមាន និន្នាការទៅរក សីលធម៌, អនេកគុណ នៃជំនឿ និង និកាយ វាទង្គិចនឹង សហធម្មិក និង ពួកបញ្ញាវន្ត ដែលមានតួនាទីសំខាន់នៅអឺរ៉ុបទំនើប។ ជាតិនិយមអាមេរិកាំង គ្មានដុតដោយភ្លើង នូវការប្រយុទ្ធនឹង សត្រូវសួពូជ ឬ ការបះបោរ ប្រឆាំងនឹង របៀបត្រួតត្រាបរទេស។

វិក្តារកម្មសេដ្ឋកិច្ច និង សំណាង បើកទ្វារដល់វិរយៈជន, បុនក្ការជានិច្ច, ការណ៍ទាំងឡាយនេះ វាមានកើតបានដោយសារ អន្តោប្រវេសន៍ និង ជនស្បែកខ្មៅ, អនុវណ្ណៈពលជីព, ភាពរាត់រាយ នៃប្រជាករ ផ្គុំដោយជាតិសាសន៍ជាច្រើន វាខាយាំងមិនអោយបង្កើតបាន នូវគណបក្សដូចជា សង្គម-ប្រជាធិបតេយ្យ នៅប្រទេស អាល្លឺម៉ង់ និងការងារ នៅប្រទេសអង់គ្លេស។ ការទាក់ទងនឹង ទំនាស់នៃប្រយោជន៍ និង ជម្លោះ នៃគំនិត វាខុសគ្នានៅអឺរ៉ុប។

នៅសហរដ្ឋអាមេរិក, ពួកអ្នកសង្គមនិយម ត្រូវគេសង្ស័យថានាំគំនិត ពួកអឺរ៉ុប ឬ មិនមែនជាគំនិតអាមេរិកាំងចូលមកក្នុងសហរដ្ឋ ដែលជាគំនិត ដែលជនជាតិអាមេរិកាំង ស្អប់ខ្ពើម នូវអត្ថាវសនិយម, ភាពឈ្លើយ និង បាបធម៌។ គំនិតជាតិនិយម អាមេរិកាំង វាដូចច្រើនទៅនឹងជំនឿស៊ប់ ប្រកបដោយមោទនភាព លើតម្លៃទោល នៃ American way of life[4] ជាង ការលូតលាស់ នៃសហគមន៍

[4] Mode de vie, របេបជីវិត។

ទាំងមូល និង ឆន្ទៈ នៃឫទ្ធានុភាព នៃអំណាច នៃរដ្ឋ ទាំងឡាយ។

គណបក្សនយោបាយនិមួយៗ មានមូលដ្ឋាន នៅតាម ដំបន់ ក៏ដូចជា ក្នុងសង្គម ដែលនាំហាមប្រើពាក្យ ខាង ឆ្វេង និង ខាងស្តាំ។ ជម្លោះសេដ្ឋកិច្ច រវាងគណបក្ស គឺជា ជម្លោះបច្ចេកទេស ហើយ មិនមែនជា ជម្លោះមនោគម វិជ្ជា។ ពួកអ្នកសេដ្ឋកិច្ចសាស្ត្រ បង្កើតទ្រឹស្តី នូវការប្រជែង សេដ្ឋកិច្ច ដែលពួកបញ្ញាវន្ត នាំគ្នាយកវាមកធ្វើជា ទ្រឹស្តី នយោបាយ នៃសមតា នៃកម្លាំង : ការសាងសង្គមមួយ ដែលបុគ្គលនិមួយ មានសេរីភាព, ស្មើគ្នា និង មាន ការ ទទួលខុសត្រូវ ឬ វាទីជន (doctrinaire) ប្រាថ្នា អោយមាន យុន្តកម្ម នៃតម្លៃ ដែលគ្មានអំណាចរដ្ឋ ជាអ្នកចាត់ចែង។ ការប្រកួត លើពិភពលោក ជាមួយនឹង សហភាពសូវៀត បង្ខំអោយបញ្ញាវន្ត មាន ការយល់ដឹងច្បាស់លាស់ អំពី ទ្រឹស្តី នៃសេរីនិយម។ សហភាពសូវៀត យកមនោគមវិជ្ជា ជាការសំអាង ដូចយ៉ាង : សង្គមគ្មានវណ្ណៈ។ សួរថា តើ សហ រដ្ឋអាមេរិក មានអ្វី សំរាប់ពាំងនឹង មនោគមវិជ្ជានេះ ? សង្គមមានសេរីភាព ជាចម្លើយនឹងសំនួរនេះ។ បដិវត្តន៍ នៃសហភាពសូវៀត វាអាចផ្ទេរបាន នៅគ្រប់ទីកន្លែង ព្រោះវាជាស្នាដៃ របស់បក្សកុម្មុយនិស្តផ្តាច់ការ និង គោល វិធីហិង្សា។ ចំណែក បដិវត្តន៍ នៃសហរដ្ឋអាមេរិក ពុំអាច

ផ្ទេរបាន ព្រោះវាសន្មត់ថាជាសកម្មភាព នៃសេរីភាព, ឯកជន និង ដើមគំនិត របស់ពលរដ្ឋម្នាក់ៗ។

## ការពិភាក្សា នៃមនោគមវិជ្ជាបារាំងសែស

ជម្លោះ នៃបញ្ញវន្តបារាំងសែស គឺមាន លទ្ធិកុម្មុយនិស្ត ជាចមបញ្ហា។ តែ បញ្ញវន្ត និយមស្តាលីន មិនស្ម័គ្រចិត្តចូលរួមពិភាក្សាពិតប្រាកដ ជាមួយនឹង ពួកអ្នកមិនមែនជាជនកុម្មុយនិស្ត។ បញ្ញវន្ត ដែលមានជំនឿស៊ប់ លើលទ្ធិកុម្មុយនិស្ត វាគ្មាន មន្ទីរពិសោធន៍, គ្មានគោលវិធី របស់ខ្លួនផ្ទាល់ លើកលែងតែនៅក្នុង ទស្សនវដ្តី របស់បក្ស។ ភាគច្រើន មិនយល់ដឹងច្បាស់ អំពី រូបធាតុនិយម វិចារវិទ្យា[5]។ ពួកជនកុម្មុយនិស្ត ជាអ្នកឯកទេសខាង នរវិទ្យា នាំគ្នាសរសេរសៀវភៅ ស្តីអំពីគុណធម៌ ដូចការស្រមៃ របស់លោក ស្តាលីន។ បញ្ហា កុម្មុយនិស្ត នៅស្រុកបារាំង ជាបញ្ហានយោបាយ ដែលគ្មានជាប់ទាក់ទងនឹង មនោសាស្ត្រសោះឡើយ។

សង្គមបារាំង ពិធុរ នូវការបង្អង់សេដ្ឋកិច្ច។ អកុសល, សំដែង ដោយ ការប្តូរ នៃ អតិផរណា (inflation) និងទំនញ់, ការគ្រងរស់ នៃសហគ្រាស ហួសសម័យ, ការរាយនៃបរិធានបង្កើតផល, ផលិតភាពទាប ក្នុងវិស័យសំខាន់

[5] Matérialisme dialectique.

នៃកសិកម្ម, ត្រូវបាន ពួកឆ្វេង និង ពួកស្តាំ បរិហារវា ជាច្រើនដង។ វិបត្តិនេះ ពង្រីកថែមឡើង ដោយ កំហុស នៃ ការធ្លាក់ចុះ នៃ ជាតប្បមាណ (natalité) និង ឧបត្ថមនិយម កសិកម្ម នៅទស្សវត្ស ៣០ និង នៅក្នុងពេលសង្គ្រាមលោកលើកទី២។
របប និង រចនាសម្ព័ន្ធ សេដ្ឋកិច្ច បែបនេះ វាគ្មាននរណាម្នាក់ចង់បាន។ ដូច្នេះ គេអាចទំលាក់កំហុសដល់ ពួកគហបតី ព្រោះគេទុកពួកនេះ ជាអ្នកដឹកនាំសេដ្ឋកិច្ច។ តែ ទាំងពួកអ្នកដឹកនាំត្រីស្ត, អ្នកនយោបាយ, អ្នកបោះឆ្នោតសមញ្ញ សុទ្ធតែចង់បាន នូវវិធានការ ដែលទប់បន្ថិចម្តងៗ នូវការរីកចំរើន, ដូចយ៉ាង ជនជាតិបារាំងចូលចិត្តរួម នូវការកំសាន្ត ទៅ ការលើកឋានៈជីវភាព, ការឧបត្ថមជន និង វិភាជន៍ (ប្រាក់បំណាច់) នៃរដ្ឋ ជាងភាពតឹងរ៉ឹង នៃការប្រកួតប្រជែង។
បញ្ញាវន្តបារាំងសែស បង្កើត នូវ កលល្បិច នៃទស្សនៈជាច្រើន សំរាប់ពិភាក្សា ព្រោះខ្លួន មាន ចំណូលចិត្ត លើការជជែកអំពីគំនិតគ្រប់បែបយ៉ាង រហូតជួនកាល គំនិតនោះ វាមិនអាចយកវា មកអនុវត្តបានផង។ ការពិភាក្សាលើវិស័យសេដ្ឋកិច្ច និង ការទូត, ពួកបញ្ញាវន្ត ចូលចិត្តជជែកគ្នា ក្នុងន័យមនោគមវិជ្ជា។ ស្រុកបារាំង មិនជាអ្នកបង្កើត ស្ថាប័នសេដ្ឋកិច្ច និង នយោបាយ ដែលមានលក្ខណៈជាលោកទំនើប តែជាអ្នកបង្កើត ជាបែបផែន

នូវពួកឆ្វេងអឺរ៉ុប គឺ ៖ សមភាព នៃមនុស្សលោក, សេរីភាព នៃពលរដ្ឋ, វិទ្យាសាស្ត្រ និង សេរីភាពក្នុងការយល់ឃើញ, បដិវត្តន៍ និង ការរីកចំរើន, ឯករាជ្យ នៃប្រជាជាតិ, សុទិដ្ឋិនិយមជាប្រវត្តិសាស្ត្រ។

## នៅប្រទេសមិនមែនជាមស្ជិមប្រទេស

បញ្ញវន្តជាទូទៅ គ្រាំចិត្ត នូវអនានុភាព នៃខ្លួន ដែលខ្លួនប្រាថ្នាចង់ប្តូរ នូវចរន្ត នៃព្រឹត្តិការណ៍ តែខ្លួនស្គាល់ នូវឥទ្ធិពល នៃខ្លួន នៅក្នុងការពិភាក្សាថ្នាក់ជាតិ។ ពួកសាវ័ក របស់សាស្ត្រាចារ្យ ឬ អ្នកនិពន្ធ ពិស្សុត ទៅអនាគតក្លាយជាអ្នកដឹកនាំ ហើយច្រើនយក គោលលទ្ធិ ឬ ទ្រឹស្តីដែលខ្លួនបានរៀន ឬ យល់ស្រប មកអនុវត្ត។ នៅប្រទេសមិនមែនជាមស្ជិមប្រទេស ក្នុងន័យរីកសាយ នៃបញ្ញវន្តគឺជា ពួកអ្នកមានសញ្ញាប័ត្រ ដែលមានតួនាទី ជាអ្នកយកចំណេះរបស់ខ្លួន មកអនុវត្ត ដើម្បីប្តូរ នូវចរន្តព្រឹត្តិការណ៍ របស់ប្រទេសខ្លួន។ តួនាទីខ្លឹម នៃបញ្ញវន្តនៅអាស៊ី វាមានចំណូលចិត្តទៅរក លទ្ធិម៉ាក្ស ដែលខ្លួនទុកជាគំនិតជឿនលឿននិយម ធ្លាប់បានរៀនវា ពីមហាវិទ្យាល័យ នៅមស្ជិមប្រទេស។ គំនិតនេះ គឺពួកសាស្ត្រាចារ្យជឿនលឿននិយម គេអប់រំដល់ពួកបញ្ញវន្ត នៃសង្គមបូរាណ អោយប្រឆាំងនឹង ការគ្រោបសង្កត់ នៃមស្ជិម

ប្រទេស។ អ្វីដែលជាការចម្លែក ហើយអស់សំណើច គឺថា ការប្រឆាំងនោះឯង វាទៅជាការប្រឆាំងនឹង គោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យទៅវិញ ដែលជាខ្លឹមសារ នៃមស្ឈិមប្រទេស ផ្ទុយពី សង្គមនៅអាស៊ី ដែលជា សង្គម អសមភាព, ឋានានុក្រមបិទទ្វារ និង គ្រោបសង្កត់ ពីសំណាក់វណ្ណៈអ្នកដឹកនាំបន្តត្រកូល។ ដូចយ៉ាង ពួកកុម្មុយនិស្តអាស៊ី យកគោលលទ្ធិម៉ាក្ស សំរាប់ប្រឆាំងនឹង មស្ឈិមប្រទេស ព្រោះទុកជា អ្នកជញ្ជក់ផលប្រយោជន៍ ពីប្រទេសខ្លួន តែយកលទ្ធិផ្តាច់ការ មកអនុវត្ត បន្តពីរបបសក្តិភូមិ។

ដូច្នេះ មស្ឈិមប្រទេស វាជា គំរូ តាមចំណេះ និង ជា សត្រូវតាមការពន្យល់ផង ចំពោះបញ្ញាវន្តអាស៊ី។ ការលាយគ្នារវាង វប្បធម៌មរតក របស់ខ្លួន និង វប្បធម៌ខ្ចី ពីមស្ឈិមប្រទេស នាំអោយបញ្ញាវន្តអាស៊ី មានអារម្មណ៍មិនពិតទៅលើ លទ្ធិប្រជាធិបតេយ្យមស្ឈិមប្រទេស ដែលនាំអោយមានការពិបាកច្រើនក្នុងការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យសេរី។

## ករណីនៅស្រុកខ្មែរ

សង្គមបូរាណខ្មែរ ជាសង្គមសក្តិភូមិ ដូចគ្នានឹងរបបដឹកនាំនោះដែរ។ មហិទ្ធានុភាព នៃសម័យមហានគរ គឺផ្អែកលើ ឬទ្ធានុភាពយោធា។ ដូច្នេះ អធិរាជអាណាចក្រ

ខ្មែរ ទទួលរងវាសនា ដូចគ្នានឹង មហានគរដទៃទៀតនៅលើពិភពលោកនោះដែរ គឺ នៅពេលដែលខ្លួនបាត់ នូវចេស្តាយោធា គឺនាំអោយបែកបាក់ នូវស៊ុម នៃអំណាចមជ្ឈឹម។ ការបង្ក នៃបញ្ញាខ្មែរ មានមូលដ្ឋានចេញពីព្រហ្មញ្ញសាសនា។ ទោះបី សង្គមភាវរូបខ្មែរ ស្ថិតនៅក្នុងសភាពនឹងថ្កល់ តែបញ្ញាខ្មែរ មានការវិវត្តន៍ ទៅតាមចរន្ត នៃមនុស្សជាតិ ដែលអាចបង្កើតបាន នូវវប្បធម៌មួយល្បីល្បាញនៅអាស៊ីបែកអាគ្នេយ៍។ ទោះបី វប្បធម៌ខ្មែរ ទទួលឥទ្ធិពលពីឥណ្ឌា តែក្រោមឥទ្ធិពលនេះ បុព្វបុរសខ្មែរ បានច្នៃប្រឌិតទៅតាមការប្រសប់ របស់ខ្លួន ដែលអាចពន្លិចចេញបាន នូវទេពកោសល្យ ពិសេសខ្មែរ។ អ្វីដែលខ្មែរខ្ចីពីបរទេស បុព្វបុរសខ្មែរ តែងតែយកមកធ្វើ ខ្មែររូបណីកម្មជានិច្ច : អាទិទេពឥណ្ឌា ក្លាយជា ព្រះខ្មែរ, រឿងរាមាយាណមា ក្លាយជា រាមកេរ្តិ៍ ដែលមានខ្លឹមសារ នៃរឿង ខុសគ្នាមួយចំនួនពីឥណ្ឌា។

វប្បធម៌ខ្មែរ ជា សារៈសិល្បៈ ដូចមានប្រាសាទអង្គរវត្ត ជានិមិត្តរូប។ ដូច្នេះ វាមានលក្ខណៈ ជា អភិរក្ស។ ទោះបី ខ្មែរមាន ភាពសម្បូណ៌ នៃអក្សរសាស្ត្រ តែ សិល្បៈ ជាខ្សែលយនៃវប្បធម៌ខ្មែរ។ វប្បធម៌នេះ សិរិ[6] នូវវត្ថុជាតុសំខាន់ពីរ : សិល្បៈ នៃការរស់នៅ និង សោភ័នភាព។ អារម្មណ៍ គ្មានឈប់ឈរ នៃការរស់នៅខ្មែរ គឺ ការគោរព នៃប្រពៃណី និង

[6] Réunir, combiner ; រួមគ្នា។

ត្បិតតែងផ្ទះសំបែង។ គ្រប់ជ្រុង ក្នុងផ្ទះ និង ទីធ្លា ជាកន្លែង រចនា នូវសោភ័នភាព។ គ្រប់ជំហាន នៃជីវិត គឺដើរតាមទំនៀមជាតិ : ខ្មែរ ទុក សយម្ភូតភាព[7] ជា ការរានទីដល់ប្រពៃណី។ ប្រាសាទខ្មែរបុរាណទាំងឡាយ បញ្ជាក់បង្ហាញ នូវការស្វែងរក នៃសោភ័នភាពពិត របស់មនុស្សលោក តែនៅសណ្ដាប់ធ្នាប់ខ្មែរ។

គំនិតសំខាន់ទាំងពីរនេះឯង ដែលជាមូលហេតុជម្រៅ នៃឥរិយាបថរួម របស់បញ្ញវន្តខ្មែរ : ជា ឥរិយាបថ យល់ព្រមក្នុងប្រព័ន្ធគំនិត អភិរក្សនិយម, ការគោរពអាជ្ញាធរ និងការគោរព នៃអគ្គជន ដូចយ៉ាង ព្រះមហាក្សត្រ, គ្រូអាចារ្យ, មាតាបិតា។ គេសង្កេតឃើញថា ប្រធានបទ នៃអក្សរសិល្បខ្មែរច្រើនតែអភិប្រាយអំពីទំនាស់ រវាង ករណីយកិច្ច និង សេចក្ដីស្នេហា នឹង ករណីយកិច្ច។

ផុសនា[8]នឹង វប្បធម៌បរទេស ជាពិសេស វប្បធម៌ បារាំងហាក់ដូចជា អ្នកចេះដឹងខ្មែរ ទទួលយក វប្បធម៌នោះ នៅក្នុងគំនិតអភិរក្សនិយម ដូចយ៉ាង មិនជំទាស់នឹងសាសនាកាតូលិក តែក៏មិនទទួលយកមកជំនួសពុទ្ធសាសនា។ តាមការណ៍ពិត អាណានិគមបារាំងនៅស្រុកខ្មែររក្សា នូវគោលការណ៍មូលដ្ឋានខ្មែរទាំងស្រុង គឺ ការគោរពនៃអាជ្ញាធរ និង អគ្គជន។ ដូច្នេះ ក្នុងរយៈពេល៩០ឆ្នាំ

---

7 Spontanéité, ការធ្វើអ្វីដោយខ្លួនឯង។
8 ការសេពគប់, កុងតាក់។

ដែលបារាំងត្រួតត្រាខ្មែរ, បារាំងសែស មិនបានធ្វើកំណែទំរង់ នូវចិត្តគំនិត នៃអ្នកចេះដឹងខ្មែរនោះទេ។ រយះពេលនោះ វាគ្រាន់តែជា វង់ក្រចក នៃការរស់នៅរួម រវាង រាជសក្តិ នឹង អំណាចអាណានិគម ដែលមានទម្រង់ដូចគ្នាបេះបិទ។ ស្ថាប័ន សភា បង្កើតឡើង បន្ទាប់ពីស្រុកខ្មែរទទួលបានឯករាជ្យ ប្រព្រឹត្តទៅដោយសណ្តាបបំផុត។ គណបក្សប្រជាធិបតេយ្យ ដែលទុកជាគណបក្សអ្នកកែប្រែ ទទួលបានជោគជ័យជាក់ស្តែងពិត នៅក្នុងល្បែង នៃលទ្ធិប្រជាធិបតេយ្យ តែពួកអ្នកដឹកនាំ សុទ្ធតែជាអ្នកអភិរក្សប្លុងចិត្ត។ អ្នកមានសញ្ញាប័ត្រជាន់ខ្ពស់បារាំងសែសមួយក្តាប់ដៃ ដែលទុកខ្លួនជាអ្នកជឿនលឿននិយម បានធ្វើការរិះគន់លើប្រព័ន្ធសង្គម តាមតែទ្រឹស្តី ដែលខ្លួនបានរៀនចេះ តែនៅក្នុងជម្រៅចិត្តខ្លួន គឺនៅជាអ្នកអភិរក្សជានិច្ច។ ដូចយ៉ាង ពួកកុម្មុយនិស្តខ្មែរ ទទួលបានអំណាច តែមិនអាចយកអ្វីថ្មី មកជំនួសអំណាចចាស់ហើយនាំគ្នាបន្តដឹកនាំជាតិ តាមប្រព័ន្ធអំណាចនេះដដែល គឺ អំណាចសមស្ត[9]។ រហូតមកដល់សព្វថ្ងៃ អំណាចនេះ នៅជាអំណាចធរមាន នៅស្រុកខ្មែរ។

ដូចយ៉ាងនេះ វាអាចអោយយើងសន្និដ្ឋានបានថា អ្នកចេះដឹង ឬ មានសញ្ញាប័ត្រខ្មែរជាទូទៅគ្រប់ជំនាន់ គាត់គ្មាន មនោគមវិជ្ជានយោបាយច្បាស់លាស់ ដែលនាំអោយ

[9] អំណាចបង្ខំប្រជាពលរដ្ឋអោយធ្វើតាម។

គ្មានការពិភាក្សាជាជម្រៅ សំរាប់ជាពន្លឺបញ្ញា ដល់ប្រជាពលរដ្ឋខ្មែរ។ កត្តាបី បញ្ជាក់ អំពីអវត្តមាន នៃការពិភាក្សានេះ គឺ បែបបទ នៃជាតិខ្មែរ នៃការទទួលឥទ្ធិពលបរទេស, ឥរិយាបថ ចំពោះសសានា និង អតីតកាល, កម្លាំង ពាក់ព័ន្ធនឹងនយោបាយ។

## ១. បែបបទ ជាតិខ្មែរ នៃការទទួលឥទ្ធិពលបរទេស

ស្រុកខ្មែរ តាមការបង្ហាញ នៃប្រវត្តិសាស្ត្រខ្លួន បានទទួលឥទ្ធិពលបរទេសសំខាន់ពីរ គឺ វប្បធម៌ឥណ្ឌា និង បារាំង នៅក្នុងមជ្ឈដ្ឋាន អ្នកដឹកនាំ និង អ្នកចេះដឹង។

## មូលដ្ឋានឥណ្ឌា

វប្បធម៌ឥណ្ឌា ហូរចូលស្រុកខ្មែរ តាមផ្លូវសង្គ្រាម។ ព្រះបាទ ហ៊ុន ទៀន ជនជាតិឥណ្ឌា មកពីឥណ្ឌា តាមផ្លូវសមុទ្រ ជាអ្នកឈ្នះសង្គ្រាមលើខ្មែរ ទ្រង់បង្ខំអ្នកដឹកនាំខ្មែរ ឈ្មោះព្រះនាង លិរ យិ អោយទទួលវប្បធម៌ឥណ្ឌា តាមអំណាចជាអ្នកឈ្នះ និង តាមសម្ព័ន្ធអាពាហ៍ពិពាហ៍ រវាងព្រះអង្គនឹងព្រះនាង លិរ យិ។ ថ្នាក់ដឹកនាំកំពូលខ្មែរ ទទួលយកវប្បធម៌ឥណ្ឌា តាមសម្រួល ព្រោះមើលឃើញថា វប្បធម៌នេះខ្ពង់ខ្ពស់ជាងវប្បធម៌ខ្លួន មិនតែប៉ុណ្ណោះ វប្បធម៌នេះផ្តល់នូវកិត្តិយស និង ប្រយោជន៍ថ្មី ដល់ពួកខ្លួន គឺ បន្ថែរជា វណ្ណៈមានពីកំណើត និង តពូជ មានឈ្មោះថា វណ្ណៈ

ក្សត្រិយៈ។ ចំណែក វិស័យការចេះដឹង គឺ ពួកព្រាហ្មណ៍ ជាអ្នកដឹកនាំដោយជំនាញ ផ្តាច់មុខ ក្នុងតួនាទី ជា វណ្ណៈបព្វជ្ជា និង គ្រូអាចារ្យ ដល់ថ្នាក់ពួកអ្នកដឹកនាំទូទាំងប្រទេស។ នៅសម័យមហានគរ មានមជ្ឈមណ្ឌលអប់រំជាន់ខ្ពស់នៅរាជធានី សំរាប់អប់រំបុត្រា ពួកស្តេចត្រាញ់ និង ខែត្រ នៅក្នុងព្រះរាជាណាចក្រ តែមិនធ្វើបរិវត្ត ពួកនិស្សិត អោយទៅជាព្រាហ្មណ៍នោះឡើយ ព្រោះ ព្រាហ្មណ៍ជាវណ្ណៈមានពីកំណើត។ ចំណែក រាស្រ្ត បន្តរស់ជាធម្មតានៅក្នុងប្រពៃណី, ជំនឿ និង ទីកន្លែង របស់ខ្លួន នៅក្នុងសង្គម អសមភាពនិយម និង បែងចែកថ្នាក់។ ដូច្នេះ រាស្ត្រខ្មែរ រស់នៅក្រៅប្រព័ន្ធ នៃវណ្ណៈអ្នកដឹកនាំ គឺថា នៅក្រៅប្រព័ន្ធ អភិវឌ្ឍន៍ នៃបញ្ញា។ វណ្ណៈអ្នកដឹងនាំ ភាគតិចគឺជា សំណង់តាមគំរូឥណ្ឌា។ គំរូនេះ កសាង ដោយវណ្ណៈក្សត្រិយៈយោធានិយម ដែលវានាំ លៃចែកស្រុកខ្មែរជាពីរសង្គម : សង្គម នៃអ្នកដឹកនាំភាគតិច តែជាអ្នក មានគ្រប់បែបយ៉ាង : សម្ភារៈ និង បញ្ញា។ ចំណែក រាស្ត្រ រស់នៅក្នុង សង្គមភាគច្រើន មាន ជីវភាពក្រលំបាក និង គ្មានប្រាជ្ញា។

ការអប់រំខ្មែរ នៅសម័យមហានគរ ដែលទទួលឥទ្ធិពលពីឥណ្ឌា គឺអប់រំ បែបអភិរក្ស : សណ្តាប់ធ្នាប់ ជាកត្តា នៃស្ថិរភាពសង្គម។ សង្គម ត្រូវមានសណ្តាប់ធ្នាប់ ដែលមានព្រះមហាក្សត្រ ជាអ្នកថែរក្សា ដោយការចាំបាច់។ ការអប់រំ

បែបនេះ ជំរុញអោយគោរពបុគ្គល នាំអោយខ្សោយរដ្ឋ។ និស្សិតទទួលការអប់រំ គ្មានដឹងអ្វី ពីការចេះដឹង របស់ខ្លួន ព្រោះ វាជាកាតព្វកិច្ច ដែលខ្លួនត្រូវធ្វើចំពោះព្រះមហាក្សត្រ។ ដូច្នេះ ត្រូវរៀនសូត្រអោយដូចគ្រូទើបទុកជាអ្នកចេះ តែមិនរវល់ដឹង អំពីសារជាតិ នៃចំណេះ។ ការចេះបែបនេះ ហៅថា សទ្ធាន្តនិយម នៃចំណេះ[10] ដែលអ្នកចេះទទួលយកវាដោយគ្មានលក្ខខណ្ឌ។

## ឥទ្ធិពលបារាំង

បារាំងត្រួតត្រាស្រុកខ្មែរអស់រយះពេល៩០ឆ្នាំ។ គេ រក្សា នូវបុគ្គលពិសិដ្ឋ នៃព្រះមហាក្សត្រទាំងមូល។ ម្លោះហើយ គេមិនធ្វើកំណែទំរង់ចិត្តគំនិតខ្មែរតាមការអប់រំនោះឡើយ។ អភិរក្សនិយម ជាគោលការណ៍មូលដ្ឋាន នៃអាណានិគមបារាំង។ ការបញ្ចូល ភាសាបារាំង, វិទ្យាសាស្ត្រជាន់ដំបូង និង បច្ចេកទេស មកក្នុងប្រព័ន្ធអប់រំខ្មែរ គឺធ្វើសំរាប់សំរួលដល់ការទំនាក់ទំនង រវាង អាជ្ញាធរអាណានិគម និង អ្នករាជការខ្មែរធ្វើការបំរើបារាំង ដើម្បី បារាំងសែស គេស្រួលត្រួតត្រា។ ជាការពិតហើយ, អាណានិគមបារាំង គេបានធ្វើការកែទំរង់ នូវរចនាសម្ព័ន្ធ នៃរបៀបដឹកនាំខ្មែរ តែមិនប៉ះពាល់ដល់សង្គមនិម្មាណ[11] ព្រោះវាជាមូលដ្ឋាន

10 Dogmatisme de la connaissance ; ការជឿម៉ឺងម៉ាត់ ទៅលើចំណេះ។
11 កម្រងសង្គម, structure sociale.

នៃអភិរក្សនិយម ដែលបារាំង គេទុកជាកត្តា នៃស្ថិរភាព នៃអាណានិគម។ នៅត្រង់ចំណុចនេះ វាមានដំណូចនឹង ចិត្តគំនិត វណ្ណៈអ្នកដឹកនាំ និង អ្នកចេះដឹងខ្មែរនៅ សម័យនោះ ដែលសុទ្ធជាអ្នកអភិរក្សនិយម។ ដូច្នេះ អាណា និគមបារាំង នាំមក នូវវិទ្យាសាស្ត្រជាន់ដំបូង តែ មិន យកមកអនុវត្ត នូវគំនិតថ្មីសំរាប់ធ្វើការកែទំរង់ នូវ សង្គមសក្តិភូមិនោះឡើយ។ បន្ទាប់ពីស្រុកខ្មែរ បានទទួល ឯករាជ្យបរិបូណ៏, នៅពេលនោះ ជនខ្មែរ ដែលបានមក សិក្សានៅស្រុកបារាំង ហើយទទួលបាន នូវសញ្ញាប័ត្រ បារាំង មានចំនួនតិចណាស់ ហើយភាគច្រើន ជាអ្នក បច្ចេកទេសទៅទៀត ដូច្នេះ ជនទាំងនោះ មិនអាចជា កម្លាំងចលករ សំរាប់ធ្វើការកែទំរង់សង្គមខ្មែរបាននោះ ឡើយ ផ្ទុយទៅវិញ ភាគច្រើន គឺមានតែយក នូវ កិត្យានុភាព នៃសញ្ញាប័ត្របរទេសនោះ មកស្វែងរក ប្រយោជន៏ផ្ទាល់ខ្លួនទៅវិញ។ ចិត្តគំនិតបែបនេះ នាំឲ លិចក្នុងអំពើអាក្រក់គ្រប់បែបយ៉ាង ឆាប់រហ័សណាស់ ក៏ ដូចពួកអ្នកលូង់ខ្លៅនោះដែរ។ ចំណែក អ្នកចេះដឹងអាយ វិញ រស់នៅក្នុង ពុម្ភសង្គមអភិរក្សនិយម តាំងពីកំណើត ហើយ បន្តចិត្តគំនិត របស់ខ្លួន តាមទម្លាប់ ដែលខ្លួន បានទទួល តាំងពីកុមារភាពមកម្លេះ។ ចំពោះអ្នកចេះ ដឹងខ្មែរភាគច្រើន យកការចេះដឹងជា សញ្ញា នៃវិសិដ្ឋ ភាព រហូតមាន សេយ្យមានះ ទៅលើ អ្នកគ្មានចំណេះវិជ្ជា

ដែលនាំអោយ បង្កើតជាវណ្ណៈ ឬ ស្រទាប់ នៃអ្នកចេះដឹង រស់ជា ដៃគូរុចិរ[12] ជាមួយនឹង វណ្ណៈអ្នកដឹកនាំ ដូចសម័យបុរាណ និង សម័យអាណានិគមបារាំង។

## ២. ឥរិយាបទ ចំពោះសាសនា

សាសនាពីរ បានជ្រាបចូលក្នុងសង្គមខ្មែរ តាំងពីបុរាណកាលមក គឺ ព្រាហ្មណ្ឌសាសនា នៅក្នុងមជ្ឈដ្ឋាន នៃអ្នកដឹកនាំ និង អ្នកចេះដឹង និង ពុទ្ធសាសនា នៅក្នុងមជ្ឈដ្ឋាន នៃប្រជារាស្ត្រ។ ព្រាហ្មណ្ឌសាសនា ជាសាសនា មានអាទិទេព, ចំណែកពុទ្ធសាសនា ជាសាសនា គ្មានអាទិទេព។ ព្រាហ្មណ្ឌសាសនា កំណត់លំដាប់ថ្នាក់ នៃតម្លៃជំនឿ ទៅលើ អាទិទេព ហើយបែងចែកសង្គមជាវណ្ណៈ សំរាប់រក នូវសុខដុម នៃការរស់នៅ ដែលមានអាទិទេព ជានិយតករ។ រីឯ ពុទ្ធសាសនា បង្ហាញផ្លូវ សីលគន្ធ សំរាប់ស្វែងរកផ្លូវចាកទុក្ខ ដើម្បី ទទួលបានសេចក្ដីសុខនៅជាតិក្រោយ។ នៅក្នុងចិត្តគំនិត អ្នកដឹកនាំ តែងទុកខ្លួនជា អវតា នៃអាទិទេព ដែលហៅថាជំនឿ ចំពោះទេវរាជ ឬ ព្រះមហាក្សត្រ-អាទិទេព។ ចំណែក ប្រជារាស្ត្រវិញ រស់នៅក្នុងជំនឿ ចំពោះកម្មផល ឬ បុណ្យ-បាប : នាកាល ដែលខ្លួនកំពុងរស់ គឺជា ផ្លែផ្កា នៃអំពើ ដែលខ្លួនបានកសាងពីអតីតជា

[12] Partenaire harmonieux ; ដៃគូផ្អែមល្ហែម។

តិ។ កម្មផលនេះ ត្រូវតែទទួល ហើយខំស្វែងរកផ្លូវល្អ ដើម្បីធ្វើអោយបានប្រសើរ សំរាប់ជាតិក្រោយ បន្តៗទៀត រហូតរកឃើញ នូវផ្លូវនិព្វាន ដូចព្រះដ៏មានព្រះភាគ។ តាមពិតមូលដ្ឋានសាសនាទាំងពីរ មានជាតុតែមួយ គឺ ការលះបង់នៃការពិត[13] ដែលកំពុងរស់នៅ : ព្រាហ្មញ្ញសាសនិកប្រគល់វាសនា របស់ខ្លួនអោយអាទិទេព ជា អ្នកដោះស្រាយ។ ការប្រឹងប្រែង ដែលខ្លួនត្រូវធ្វើចំពោះមុខបញ្ហា នៃជីវិតពិត គឺ ការបន់ស្រន់ សូម នូវអន្តរាគមន៍ ពីអាទិទេព ដែលខ្លួនទុកជា ការកំណត់ទោល[14] សំរាប់ដោះស្រាយនូវបញ្ហា។ ចំណែក ពុទ្ធសាសនិក វិញ ទុក នូវទុក្ខវេទនារបស់ខ្លួន ជា លទ្ធទុក្ខ[15] គ្មានដំណោះស្រាយនោះឡើយ សំរាប់ជីវិត ដែលកំពុងរស់នៅ ព្រោះវាជាកម្មផល ដែលត្រូវតែទទួលសិន។ ដូច្នេះ ការលះបង់ នៃការពិត គឺ ការមិនទទួលខុសត្រូវ ចំពោះខ្លួនឯង តែម្តង។ ជាមួយនឹង ចិត្តគំនិត ជាអ្នកអភិរក្សនិយម ជាមរតកសង្គម ខ្មែរភាគច្រើន ជាពិសេស ពួកអ្នកដឹកនាំ និង អ្នកចេះដឹង មិនយក ការទទួលខុសត្រូវ ជាគោលការណ៍ នៃអំពើ ដែលខ្លួនបានប្រព្រឹត្តិនោះឡើយ ព្រោះថា ក្នុងឋានៈខ្ពង់ខ្ពស់ របស់ខ្លួន, ខ្លួនគ្មានការតព្វកិច្ចអ្វីនឹង ទទួល នូវការខុសត្រូវ

13 Refus de l’objectivité.
14 Paramètre unique.
15 Peine acquise.

ចំពោះ ទុក្ខអ្នកដទៃនោះឡើយ ព្រោះថា ទុក្ខនោះ វាកើត ពីឆន្ទៈ នៃអាទិទេព ឬ ពីកម្មផលពីអាតីតជាតិ។

## ៣. កម្លាំង ពាក់ព័ន្ធនឹងនយោបាយ

កម្លាំង ពាក់ព័ន្ធនឹងនយោបាយ គឺ កម្លាំងបាយហិង្សា។ តាមប្រពៃណីខ្មែរ វាគ្មានសោះឡើយ នៅក្នុងជីវិតភាព នយោបាយ នូវកម្លាំងប្រឆាំងនឹងអ្នកដឹកនាំ និង ការ ពិភាក្សាផ្ទុយមតិគ្នា។ អំពើនេះ ទុកជា អំពើក្បត់ជាតិ : ជនណា មិនព្រមដើរតាមនយោបាយ របស់អ្នកដឹកនាំ ត្រូវតែប្រលះពីសង្គមជាតិ ព្រោះវា ជាវត្ថុធាតុអាក្រក់។ អំណាចផ្តាច់ការ នៃអ្នកដឹកនាំខ្មែរគ្រប់ជំនាន់ ជា មនោ គមវិជ្ជានយោបាយ មានប្រភពចេញពីរាជសក្តិ[16] ក្រោម ទម្រង់ នៃរជ្ជព្រហ្មញ្ញសាសនា និង រជ្ជពុទ្ធសាសនា។ ដូច្នេះ នៅក្នុងមជ្ឈដ្ឋាន នៃអ្នកចេះដឹង ដែលជា អនុមជ្ឈដ្ឋាន នៃអ្នកដឹកនាំ គ្មានការពិភាក្សាគំនិតនោះឡើយ ព្រោះ មនោគមវិជ្ជា របស់អ្នកចេះដឹង គឺ អភិរក្សនិយម ដែល មាន ព្រះមហាក្សត្រ ឬ អ្នកដឹកនាំជាតិ ជាអ្នកថែរក្សា នៃ សណ្តាប់ធ្នាប់សង្គមអភិរក្ស។

[16] Pouvoir royal.

# សេចក្តីសន្និដ្ឋាន

ព្រឹត្តិការណ៍រពើតរពើង មានកើតឡើង តាំងពីស្រុកខ្មែរទទួលបានឯករាជ្យ គឺ កើតឡើងពីការរក្សាបរិសុទ្ធ នូវមនោគមវិជ្ជានយោបាយខ្មែរ មានតាំងពីបុរាណកាលមក។ ឥទ្ធិពល ដែលពួកអ្នកដឹកនាំជាតិ និង អ្នកចេះដឹងបានទទួល ពីឥណ្ឌា ពីបារាំង ពីប្រទេសជិតខាង និង ពីប្រទេសដទៃទៀតក្តី គឺ ពួកនោះ យកមកប្រលេះយកតែគំនិតណា ដែលវាសម ទៅតាមតែ ចិត្តគំនិតផ្តាច់ការរបស់ខ្លួន : ចំពោះពួកអ្នកដឹកនាំ គឺ អញនិយម, រីឯ ពួកអ្នកចេះដឹង វិញ គឺ សេយ្យមានះ ចំពោះមុខប្រជារាស្ត្រ។ ចិត្តគំនិតទាំងពីរនេះ បង្កជា អំពើផ្តាច់ការ ដែលហៅថាលទ្ធិផ្តាច់ការ នៃវណ្ណះ។ រជ្ឈសញ្ញា[17] រវាង រាស្ត្រ និង ពួកទាំងពីរខាងលើនេះ គឺ វាមិនផ្សាប់គ្នា, គឺថា ទុកជា ចន្លោះចំហដែល រាស្ត្រ គាត់មិនអាចឆ្លងកាត់ ដោយគ្មានទោសបាននោះឡើយ។ តែត្រូវដឹកថា ប្រជារាស្ត្រខ្មែរ គាត់ក៏មិនដែលមានសោះ នូវឆន្ទះនឹងឆ្លងកាត់នោះដែរ ដែលនាំអោយលទ្ធិនេះ វារចនាបានជា មនោគមវិជ្ជាមាំមួនបំផុត នៅក្នុងសង្គមខ្មែរ។ តែគេអាចនឹកក្នុងចិត្តបានថា ចុះហេតុអ្វីបានជា ពួកខ្មែរក្រហម និង ពួកអ្នកដឹកនាំបច្ចុប្បន្នដែលមាន កំណើតជា រាស្ត្រសុទ្ធសាធ អាចឡើងកាន់

[17] Trait d’union.

អំណាចបាន ? ពួកទាំងពីរនេះ មិនមែនឡើងកាន់អំណាចដោយខ្លួនឯងបាននោះឡើយ, ដូចយ៉ាង: ពួកខ្មែរក្រហម គឺ ចិនកុម្មុយនិស្ត និង អាមេរិកាំង ត្រូវគ្នា នាំគ្នាលើកពួកនេះ អោយឡើងកាន់អំណាច។ ចំណែក ពួកអ្នកដឹកនាំសព្វថ្ងៃ គឺ យួនកុម្មុយនិស្ត គេយកមកបន្ទើរលើអំណាច ដើម្បីបំរើប្រយោជន៍យួនតែប៉ុណ្ណោះ។ តែត្រូវដឹងថា នៅពេលពួកនេះមកកាន់អំណាច ទោះជា អំណាចសិប្បនិម្មិត ឬ បំរើបរទេសក្តី គឺ ពួកនោះយកចរិត ជាជនផ្តាច់ការ សំរាប់ត្រួតត្រាប្រជារាស្ត្រ ដែលជាប្រភព នៃកំណើត របស់ខ្លួន។ គេនឹកក្នុងចិត្តថា តើស្រុកខ្មែរ ឬសង្គមខ្មែរ ជាប្រទេសមួយ ដែលមិនអាចនឹងធ្វើកំណែទំរង់បាន សោះអី ? របបសង្គមរាស្ត្រនិយម, សាធារណរដ្ឋខ្មែរ, កម្ពុជាប្រជាធិបតេយ្យ និង រាជានិយមរស់ឡើងវិញសុទ្ធតែមានឧបនិស្ស័យ ធ្វើកំណែទំរង់ប្រជាជាតិខ្មែរ ឲល្អប្រសើរ តែពួកអ្នកដឹកនាំ ពួកគាត់ តាំងខ្លួនឯកជាអ្នកចេះដឹង នាំគ្នាពាក់ងារ ជាបណ្ឌិត បន្ទួយកមនោគមវិជ្ជាចាស់ មកលាបពណ៌ថ្មី ធ្វើជាពុម្ភ នៃកំណែទំរង់ ដើម្បី បំរើប្រយោជន៍ផ្ទាល់ខ្លួន។ ចំណែក អ្នកចេះដឹង គ្រាន់តែមានសញ្ញាប័ត្រ នាំគ្នារស់រស់ សូមសុខ ឬ បំរើពួកអ្នកដឹកនាំតែម្តង។ ជាការពិតហើយ បើហ៊ានបញ្ចេញមតិជំទាស់ គឺត្រូវគេសម្លាប់ដូចលោក កែម ឡី ឬ ត្រូវជាប់គុក ដូចលោក

កឹម សុខា តែខ្មែរគួរដឹងថា គ្មានការគស្ង៉ បំរើប្រជាជាតិណាមួយ គ្មានវិរបុរសនោះឡើយ។
នៅក្នុងពិភពលោកប្បុប្បន្ន មាន ទម្រង់លោក ៦យ៉ាង : លោកប្រាកដនិយម, លោកសេរីនិយម, លោកកុលសម្ព័ន្ធនិយម, លោកម៉ាក្សនិយម, លោកបច្ចេកទេសនិយម និង លោកសង្គ្រាមនិយម, សួរថា តើស្រុកខ្មែរសព្វថ្ងៃ ស្ថិតនៅក្នុងលោកមួយណា ? បើយោងតាម មនោគមវិជ្ជាជាតិ អវិជ្ជមាន នៃអ្នកដឹកនាំសព្វថ្ងៃ, ស្រុកខ្មែរ គ្មានអត្តិភាពផ្ទាល់របស់ខ្លួនឡើយ ព្រោះ ប្រជាជាតិខ្មែរ រស់ជាប្រជាជាតិខ្ញុំ ចិន-យួន និង នៅក្នុង អនិស្សរភាពទាំងស្រុង នៃលោកកូបនីយកម្ម គ្រប់វិស័យ : នយោបាយជាតិ និង អន្តរជាតិ, សេដ្ឋកិច្ច និង នយោបាយអន្តោប្រវេសន៍របស់យៀកណាម។ ជាថ្មីម្តងទៀត ប្រជាជាតិខ្មែរ ខក នឹងឡើងជិះ រថភ្លើង នៃលទ្ធិប្រជាធិបតេយ្យ ដែល កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ បើកឱកាសអោយឡើងជិះ។ គេនឹកក្នុងចិត្តថា តើបញ្ញាខ្មែរ ដែលគេសន្មត់ថា ពួកអ្នកចេះដឹងខ្មែរ ជាអវតា វាគ្មានសោះតែម្តង ? ឬបញ្ញា នៃអ្នកចេះដឹងខ្មែរ វានៅក្រោមជានិច្ច នៃបញ្ញារបស់សពសម្តេច សីហនុ ដែល ពួកអ្នកដឹកនាំ និង ពួកអ្នកប្រឆាំង តែងតែទុកជា មរតកបញ្ញាជាតិ ? បើជាការពិតមែន, វាគួរអោយអាណិតប្រជាជាតិខ្មែរណាស់ !



**សាកល្បង**
សរសេរ ដោយ ឧប សៅ សង្ហា
១៩ មិថុនា ២០១៨